**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**រវាង**

**ក្រុមហ៊ុន ថបហ្វម (ខេមបូឌា) មេនូហ្វេកធើរីង ឯ.ក**

**ជាមួយប្រតិភូបុគ្គលិកពេញសិទ្ធិ និងប្រធានក្រុមទាំងអស់ប្រចាំក្រុមហ៊ុន**

នៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង៣០នាទីព្រឹក នៅក្នុងរោងចក្រ **ថបហ្វម (ខេមបូឌា) មេនូហ្វេកធើរីង ឯ.ក** មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងប្រតិភូបុគ្គលិកពេញសិទ្ធិ និងប្រធានក្រុមទាំងអស់ប្រចាំក្រុមហ៊ុន។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ ស្តីពី ស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុន ដែលខ្វះអ្នកបញ្ជាទិញ ដែលបណ្តាលឱ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន១២៩២នាក់ (ស្រី ១១៥៤នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៧១៤នាក់ (ស្រី ១៥២៩នាក់) សម្រាប់រយៈពេល ២ខែ ដោយគិតចាប់ពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល៥០%នៃប្រាក់ឈ្នួលប្រចាំថ្ងៃ និងរក្សាប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅរយៈពេល២ខែ។

ប្រាក់ឧបត្ថមក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនឹងបើកជូនកម្មករនិយោជិតនៅថ្ងៃទី០៧ និងថ្ងៃទី២០នៃខែបន្ទាប់។

អង្គប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោង ១០ និង ៣០នាទី ថ្ងៃខែឆ្នាំដដែលប្រកបដោយក្តីរីករាយ។

ថ្ងៃព្រហ ៦រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

កណ្តាល, ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២

**តំណាងក្រុមហ៊ុន**

**ស្នាមមេដៃប្រតិភូបុគ្គលិក**

ព្រះរាជាណាចក្រកម្ពុជា

TOP FORM (CAMBODIA) MANUFACTURING COMPANY LIMITED.

KINGDOM OF CAMBODIA

## ស្នាមមេដៃប្រតិភូបុគ្គលិក

| | | |
|---|---|---|
| សុខ ស្រីមុំ | ឆាលយ សុវណ្ណារ៉ា | លាស់ សាពរិទ្ធី |
| ភីម សុខលន | ស្រ៊ិន សុខណាប | យិន សុម៉ាលី |
| ចឹកម កំសៀន | ភីម សុខា | លី សល |
| តាស់ សារី | ម៉ុម សុភ័ក្ត្រ | ស៊ីន សុខណា |
| តាស់ ពន្លឺ | តាំង ចំណាប់ | ពេញ្ញុំ ភាព្យ |
| ចេង ស្រីវ | ស៊ីម ស្រីនាង | ស៊ុក ស្រីពៅ |